00594922

E188/4

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

កាលបរិច្ឆេទឯកសារ: ១៨ សីហា ឆ្នាំ២០១០

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមទី ៣

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: បារាំង (បកប្រែភាសាខ្មែរ)

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 20 / 08 / 2010
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

## សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុមទី ៣)

---

**ដាក់ដោយ:**

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោកស្រី Annie DELAHAIE

លោក Philippe CANONNE

លោកស្រី Elisabeth RABESANDRATANA

លោកស្រី Fabienne TRUSSES NAPROUS

**ផ្ញើជូន:**

**អង្គជំនុំជម្រះតុលាការកំពូល:**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មូណី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 08 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

00594923

E188/4

លោកស្រី Christine MARTINEAU

**ចំលងជូន:**

**ជនជាប់ចោទ:**

លោក កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្តីជនជាប់ចោទ:**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

**ការិយាល័យសហព្រះរាជអាជ្ញា:**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី:**

Me Karim Khan

Me TY Srinna

Me Alain WERNER

Me Brianne McGONIGLE

Me KONG Pisey

Me HONG Kimsuon

Me YUNG Panith

Me Silke STUDZINSKY

Me Pierre-Oliver SUR

E188/4

1. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី ៣ ដោយអនុលោមតាមបទបញ្ញត្តិ នៃវិធានផ្ទៃក្នុង សូមដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ លើសាលក្រមចេញដោយអង្គជំនុំជម្រះសាលាដំបូងនាថ្ងៃទី ២៦ កក្កដា ២០១០ ដែលប្រកាសថា ជនជាប់ចោទឈ្មោះលោក កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ជាប់ចោទពី បទឧក្រិដ្ឋកម្មរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិដូចដែលបានរៀបរាប់ក្នុងសេចក្ដីសំរេច និងបានផ្ដន្ទាទោសជនជាប់ចោទ ឲ្យជាប់ពន្ធនាគារ ៣០ឆ្នាំ ។
2. អង្គជំនុំជម្រះសាលាដំបូងប្រកាសថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ដូចដែលមាន រៀបរាប់ក្នុងកថាខ័ណ្ឌ 645 និង 650 នៃសាលក្រមបានទទួលរងនូវព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលតាមរយៈឧក្រិដ្ឋកម្មនោះ ជនជាប់ចោទ ត្រូវបានផ្ដន្ទាទោស ។ [...] អង្គជំនុំជម្រះសាលាដំបូងបដិសេធភាគីដទៃទៀត ជាដើមបណ្ដឹងរដ្ឋប្បវេណី ។
3. បណ្ដឹងសាទុក្ខនេះពាក់ពន្ធ័តែទៅនឹងបទបញ្ញត្តិលើដើមបណ្ដឹងរដ្ឋប្បវេណី ។
4. បណ្ដឹងសាទុក្ខនេះ ដោយឈរលើមូលដ្ឋាន I, II, III, IV
   ពាក់ពន្ធ័នឹងដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោម ៖
   - E2/34 SO Saung
   - D25/11 KHUON Sarin
   - E2/82 MORN Sothea
   - E2/70 CHAN Yoeurng
   - E2/71 SOEM Pov
   - E2/63 PANN Pech
   - E2/33 PHAOK Khan
   - E2/23 LAY Chan
5. បណ្ដឹងសាទុក្ខនេះ ដោយឈរលើមូលដ្ឋាន V ពាក់ពន្ធ័នឹងដើមបណ្ដឹងរដ្ឋប្បវេណី ដូចខាងក្រោម ៖
   - E2/34 SO Saung
   - D25/11 KHUON Sarin
   - E2/82 MORN Sothea
   - E2/70 CHAN Yoeurng
   - E2/71 SOEM Pov
   - E2/63 PANN Pech
   - E2/33 PHAOK Khan
   - E2/23 LAY Chan
   - E2/84 UK Va Sothin
   - E2/80 CHIN Meth
   - E2/78 MEAS Saroeun
   - E2/79 SIEK Sek
   - E2/72 KAN San
   - E2/76 HUL Voeun
   - E2/30 NHOEM Kim Hoeun

E188/4

6. បណ្តឹងសាទុក្ខនេះ គឺធ្វើឡើងស្របតាមបទបញ្ញត្តិ 105(2) a) et c) 105(3) នៃវិធានផ្ទៃក្នុង ។
7. អណត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើបណ្តឹងសាទុក្ខ មានភ្ជាប់នៅក្នុងសេចក្តីជូនដំណឹងនេះ ។

## មូលដ្ឋាននៃបណ្តឹងសាទុក្ខ

8. ឈរលើបទបញ្ញត្តិនៃវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹង រដ្ឋប្បវេណីក្រុមទី ៣ បានធ្វើឡើងដោយផ្អែកលើការភ័ន្តច្រឡំលើអង្គច្បាប់ ដែលនាំឱ្យ មោឃៈភាពលើសាលក្រមនេះ និងដោយមានការភន្ត័ច្រឡំយ៉ាងជាក់ស្តែងលើការវិនិច្ឆ័យ ។

### I. មូលដ្ឋានទី ១៖ការភ័ន្តច្រឡំលើអង្គច្បាប់ទាក់ទងនឹងការបដិសេធលើការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី

E2/23 E2/33 E2/34 E2/63 E2/70 E2/71 E2/82 D25/11

9. អង្គជំនុំជម្រះសាលាដំបូង បានសំរេចសេចក្តីពីរដំណាក់កាលលើភាពអាចទទួល យកបាននៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយមានការរំលោភទៅលើវិធាន 21(1), 21(1)(a), 21(1)(c), 23(4), 83(1) និង 100 នៃវិធានផ្ទៃក្នុង និងការអនុវត្តដែលមានអត្ថិភាពនូវចំពោះមុខស្ថាប័នអន្តរជាតិនានា។

### II. មូលដ្ឋានទី ២៖ ការភ័ន្តច្រឡំនៃអង្គច្បាប់លើបទដ្ឋាននៃការបង្ហាញភ័ស្តុតាង

10. អង្គជំនុំជម្រះសាលាដំបូងមានការភ័ន្តច្រឡំយ៉ាងពិតប្រាកដលើអង្គច្បាប់នូវគ្រង់ចំនុច ដែលថាអង្គជំនុំជម្រះខ្លួនឯងមិនបានគោរពបទបញ្ញត្តិ 23 (5) នៃវិធានផ្ទៃក្នុងលើការបង្ហាញភស្តុតាងដោយបដិសេធលើការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យ E2/23, E2/33, E2/34, E2/70, E2/82 ។ អង្គជំនុំជម្រះសាលាដំបូង មានការភ័ន្តច្រឡំលើអង្គច្បាប់ទៅលើដើមបណ្តឹង E2/23, E2/33, E2/34, E2/70, E2/82 នៃវិធាន 23 (5) (rev.3) លើការបង្ហាញភ័ស្តុតាង និងលក្ខណវិនិច្ឆ័យដែលបានទទួលស្គាល់ដោយយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិពាក់ព័ន្ធទៅនឹងការប្រកាស និងការរកឃើញអត្តសញ្ញាណសមាជិកគ្រួសាររបស់ពួកគេ នៅឯសារមន្ទីរទួលស្លែង ។

11. ការអនុវត្តដោយមិនត្រឹមត្រូវលើបទដ្ឋាននៃការបង្ហាញភស្តុតាងគឺជាការភ័ន្តច្រឡំលើ អង្គច្បាប់ ដែលនាំឱ្យមោឃៈភាពលើសាលក្រមត្រង់ចំណុចនៃការបដិសេធមិនទទួល ស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី ។

**III. មូលដ្ឋានទី ៣៖ ការភ័ន្តច្រឡំលើអង្គច្បាប់ទាក់ទងទៅនឹងចំណងញាតិលោហិត និង "ចំណងពិសេសនៃសេចក្តីស្រឡាញ់"**

12. ការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដូចដែលមាន រៀបរាប់ខាងក្រោម គឺជាការភ័ន្តច្រឡំលើអង្គច្បាប់ដែលនាំឱ្យមានមោឃៈភាពលើ សាលក្រម ដោយហេតុថាបានរំលោភបំពានលើវិធាន ២៣(២) នៃវិធានផ្ទៃក្នុង ដោយទាមទារលក្ខខណ្ឌនៃ "ចំណងពិសេសនៃសេចក្តីស្រឡាញ់" ។ អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់មួយផ្សេងទៀតដោយបានពិចារណា ថាមិនមាន "ចំណងពិសេសនៃសេចក្តីស្រឡាញ់" រវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី E2/34, E2/63, E2/71, D25/11 និងបុគ្គលនីមួយៗ ដែលបានបាត់បង់ជីវិត ដោយបានធ្វើការបកស្រាយខុសលើវិធាន ២៣(២) នៃវិធានផ្ទៃក្នុង ដែលវិធាននេះមិនមានចែងលក្ខខណ្ឌ ឬក៏បញ្ញត្តិលើកឡើងអំពី "ចំណងពិសេសនៃសេចក្តី ស្រឡាញ់" ។

13. ការភ័ន្តច្រឡំលើអង្គច្បាប់ដូច្នេះ នាំឱ្យមោឃៈភាពលើការបដិសេធមិនទទួលស្គាល់លើដើមបណ្តឹងរដ្ឋប្បវេណី ហើយ អ.ជ.ស.ដ ត្រូវតែធ្វើការកែប្រែផងដែរត្រង់ចំនុចនេះ ។

**មូលដ្ឋានទី 4៖ ការភ័ន្តច្រឡំលើអង្គហេតុជាហេតុបង្កឲ្យមានការមិនព្រមកាត់ក្តីយុត្តិនិសេធ**

14. ការបដិសេធមិនទទួលស្គាល់លើដើមបណ្តឹងរដ្ឋប្បវេណី E2/23, E2/33, E2/34, E2/70, E2/82 គឺជាការភ័ន្តច្រឡំលើអង្គហេតុដែលនាំឱ្យមាននូវការមិនព្រមកាត់ក្តីយុត្តិនិសេធ ដោយមិនទទួលដឹងឮលើរូបថតរបស់ជនរងគ្រោះផ្ទាល់ដែលត្រូវជាប់ឃុំឃាំងនៅទួលស្លែង ។ដូច្នេះ អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គហេតុដោយមិនព្រមទទួលយកមក ពិចារណានូវរូបថតមួយចំនួនដែលបានថតនៅទួលស្លែង ដែលមានទំនាក់ទំនងទៅនឹង ជនរងគ្រោះដែលបានបាត់បង់ជីវិតរបស់គ្រួសារដើមបណ្តឹងរដ្ឋប្បវេណី ។

15. វាក៏ដូចគ្នាផងដែរទៅនឹងការបដិសេធលើ ដើមបណ្តឹងរដ្ឋប្បវេណី E2/34 ដោយសំអាងថាគ្មានភស្តុតាង ដែលតាមការពិត ភស្តុតាងស្តីពីចំណងញាតិលោហិត ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងរួចរាល់ហើយ ។

<u>**មូលដ្ឋានទី 5៖ ការភ័ន្តច្រឡំលើអង្គច្បាប់ពាក់ព័ន្ធទៅនឹងការជួសជុលសំណងការខូចខាត**</u>

16. អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់ដោយធ្វើការបកស្រាយឆ្គាំឆ្គងលើមាត្រា 23 (12) នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹងសំណងសមូហភាព និងសំណងផ្លូវចិត្ត ដែលបានចែងថាសំណងត្រូវតែមានរូបភាពជាសកម្មភាព ឬជាសេវាមិនយកកម្រៃ ដើម្បីជាផលប្រយោជន៍ដល់ជនរងគ្រោះ ។

17. អ.ជ.ស.ដ មិនអនុវត្តនូវបទបញ្ញត្តិពាក់ព័ន្ធទៅនឹងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើបញ្ហាទ្រព្យសម្បត្តិដែលរឹបអូសដោយខុសច្បាប់ ឬដោយតាមទំលាប់ ឧក្រិដ្ឋ ដែលចង្អុរបង្ហាញតាមរយៈចំនុចនេះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អាចទៅឱ្យហួសពីអាណត្តិរបស់ខ្លួនក្នុងការដាក់ឱ្យមានជាសំណងជួសជុលលើការខូចខាត ។

18. អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់ដោយលើកឡើងថា ការទាមទារ សំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានភាពមិនច្បាស់លាស់ និងមិនអាចកំណត់បាន លើចំនួនទឹកប្រាក់ ព្រមទាំងការសាងសង់បូជនីស្ថាន ឬទីកន្លែងសំរាប់ធ្វើការចងចាំដែលមានចាឈ្មោះរបស់ជនរងគ្រោះ ដែលតាមការពិតទីតាំងត្រូវបានបញ្ជាក់យ៉ាង ច្បាស់លាស់ ។

19. វាមិនមែនជាតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការកំណត់ទឹកប្រាក់នៃការ ជួសជុលសំណងលើការខូចខាតទេ ។

20. អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់ដោយមិនបានឆ្លើយតបទៅនឹងការទាមទារ ឱ្យបង្កើតមាននូវមូលនិធិមួយក្នុងគោលបំណងដាក់ឱ្យមាននូវវិធានការជួសជុល ការខូចខាត ។

21. អ.ជ.ស.ដ មានការភ័ន្តច្រឡំលើអង្គច្បាប់ដោយបដិសេធ ចំណងទាក់ទងរវាងការស្នើសុំបង្កើតឱ្យមាននូវរចនាសម្ព័ន្ធសុខាភិបាល សុខភាព ការអប់រំសិក្សា ទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកាំង ហ្កេកអ៊ាវ តែដែលតាមការពិត លើបញ្ហាសុខភាព ចំណងទាក់ទងនេះគឺមានភាពជាក់ស្តែង និងលើវិស័យអប់រំសិក្សា ចំណងទាក់ទងគឺថិតលើគតិនៃដំណើរការកាត់ក្តីនេះ និងដើម្បីជៀសវាងការបំភ្លេចរបបនេះចោល ។

## <u>សេចក្ដីសន្និដ្ឋាន</u>

22. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៃក្រុម 3 នឹងដាក់មូលដ្ឋានពេញលេញ នៃបណ្ដឹងសាទុក្ខក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃដាក់សេចក្ដី ជូនដំណឹងដោយសង្ខេបលើបណ្ដឹងសាទុក្ខនេះ ។

23. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមទាមទារ៖

24. ឲ្យទទួលយកបណ្ដឹងសាទុក្ខ

25. ឲ្យយល់ព្រមទទួលយកការដាក់ឯកសារភស្ដុតាងបន្ថែម

26. លើកចោលនូវសាលក្រមរបស់ អ.ជ.ស.ដ ត្រង់ចំនុចដែលមានភាពខ្វះចន្លោះ ដូចដែលបានរៀបរាប់ពីខាងលើ ។

27. និងកាត់សេចក្ដីឲ្យឈ្នះ ដល់ការស្នើសុំពីដើមដំបូងនៅចំពោះមុខ អ.ជ.ស.ដ ដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណី ។

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ អ.ជ.ត.ក

ភ្នំពេញ 20 សីហា 2010

**Me Martine JACQUIN**
**Chef de projet ASF-France**

ធ្វើឡើងដោយសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមទី ៣

លោក គឹម ម៉េងឃី

លោកស្រី Martine JACQUIN

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Annie DELAHAIE

លោក Philippe CANONNE

លោកស្រី Elisabeth RABESANDRATANA

លោកស្រី Fabienne TRUSSES NAPROUS

លោកស្រី Christine MARTINEAU